សាជីវកម្មធានាឥណទានកម្ពុជា
CREDIT GUARANTEE CORPORATION OF CAMBODIA

ធនាគារ ឈីហ្វ
CHIEF BANK

# សេចក្តីប្រកាសព័ត៌មាន

## ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពី<br>គម្រោងធានាឥណទានបោះដុំ និងគម្រោងធានាឥណទានដើម្បីជំរុញសេដ្ឋកិច្ច<br>រវាង សាជីវកម្មធានាឥណទានកម្ពុជា និងធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក

សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក បានចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀងស្តីពីគម្រោងធានាឥណទានបោះដុំក្នុងទំហំ៥លានដុល្លារអាមេរិក (Wholesale Guarantee Scheme - WGS) និងគម្រោងធានាឥណទានជំរុញសេដ្ឋកិច្ច (Economic Stimulus Guarantee Scheme - ESGS) នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦ នៅការិយាល័យ CGCC។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាដោយ **លោក ណូ លីដា អគ្គនាយក** CGCC និង**បណ្ឌិត លឹម អូន នាយកប្រតិបត្តិធនាគារ ឈីហ្វ** ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងតំណាងនៃស្ថាប័នទាំងពីរ។

បន្ទាប់ពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃនេះ ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក បានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ CGCC ជាផ្លូវការ ដែលនឹងអនុញ្ញាតឱ្យធនាគារ ឈីហ្វ ពង្រីកការបញ្ចេញឥណទានក្រោមការធានារបស់ CGCC ទៅកាន់អាជីវកម្មសក្តានុពលនៅកម្ពុជា ជាពិសេសសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលប្រឈមនឹងបញ្ហាកង្វះទ្រព្យធានាសម្រាប់ការស្នើសុំកម្ចីពីធនាគារ។

**លោក ណូ លីដា អគ្គនាយក CGCC** បានមានប្រសាសន៍ថា *"CGCC ស្វាគមន៍នូវភាពជាដៃគូជាមួយស្ថាប័នហិរញ្ញវត្ថុដែលចូលរួម (PFIs) ដូចជា ធនាគារ ឈីហ្វ Chief ដែលទទួលស្គាល់អំពីតម្លៃនៃការធានាឥណទាន និងប្រើប្រាស់ការធានាឥណទាន ប្រកបដោយបុរេសកម្ម ដើម្បីគាំទ្រដល់អាជីវកម្មដែលមានសក្តានុពល។ ជាមួយនឹងការធានារបស់ CGCC, យើងសង្ឃឹមថា ធនាគារ ឈីហ្វ នឹងអាចពង្រីកការគាំទ្រផ្នែកហិរញ្ញវត្ថុទៅកាន់សហគ្រាសខ្នាតតូច និងមធ្យម (SMEs) ដែលមានសក្តានុពលខ្ពស់នៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ ធនាគារ ឈីហ្វ អាចផ្តល់ប្រាក់កម្ចីជាមួយនឹងសមាមាត្រកម្ចីធៀបនឹងតម្លៃទ្រព្យបញ្ចាំ (loan-to-value) ខ្ពស់ជាងមុន, រក្សាទុកបម្រុងទាបជាងមុនសម្រាប់កម្ចីដែលមានការធានា, និងអាចផ្តល់កម្ចីជូនដល់អតិថិជនដែលមិនអាចទទួលបានកម្ចី ប្រសិនបើគ្មានការធានា។ តាមរយៈភាពជាដៃគូនេះ យើងចង់ឃើញ ធនាគារ ឈីហ្វ ពង្រីកការផ្តល់កម្ចីរបស់ខ្លួន ដោយមិនចាំបាច់ពង្រីកហានិភ័យ តាមសមាមាត្រនៃការពង្រីកកម្ចី ព្រោះ CGCC នឹងចូលរួមចែករំលែកហានិភ័យ។ CGCC ប្រកាន់ភ្ជាប់ក្នុងការកែលម្អជាបន្តបន្ទាប់លើការងារអាទិភាពជាយុទ្ធសាស្ត្រចម្បង ៥៖ ដំណើរការ (Process) ភាពជាដៃគូ (Partnership) ផលិតផល (Product) មនុស្ស (People) និងគោលនយោបាយ (Policy) ដើម្បីគាំទ្រដៃគូរបស់យើង និងប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុ ឱ្យបានកាន់តែប្រសើរ។"*

**បណ្ឌិត លឹម អូន នាយកប្រតិបត្តិធនាគារ ឈីហ្វ** បានមានប្រសាសន៍ថា " ចំពោះធនាគារ ឈីហ្វ នេះជា ព្រឹត្តិការណ៍ដ៏សំខាន់មួយ និងជាជំហានឈានទៅមុខដ៏មានអត្ថន័យ ដែលបានក្លាយជាស្ថាប័នហិរញ្ញវត្ថុចូលរួម

(PFI) ជាផ្លូវការ ក្រោមកម្មវិធីធានាឥណទានរបស់ CGCC។ ភាពជាដៃគូនេះបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមគ្នារបស់យើងក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈការពង្រឹងលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់អាជីវកម្ម និងបុគ្គល ជាក់ស្តែងសម្រាប់សហគ្រាសធុនតូច និង មធ្យម (SMEs) ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា។ ″

តាមរយៈភាពជាដៃគូនេះ CGCC និងធនាគារ ឈីហ្វ មានទិសដៅក្នុងការគាំទ្រក្រុមហ៊ុន/អាជីវកម្មតាមរយៈគម្រោងធានាឥណទានចំនួនពីររបស់ CGCC គឺ WGS និង ESGS។ ក្រោមគម្រោង WGS, CGCC នឹងផ្តល់ការធានាលើកម្ចីអាជីវកម្មដែលមានស្រាប់របស់ធនាគារ ឈីហ្វ ដើម្បីចែករំលែកហានិភ័យជាមួយធនាគារ និងកាត់បន្ថយកម្រិតថ្លឹងហានិភ័យលើអ៊ិចស្ប៉ូស៊ើដែលមានការធានា។ តាមរយៈ WGS ធនាគារ ឈីហ្វ នឹងអាចពង្រីកលទ្ធភាពក្នុងការផ្តល់កម្ចីរបស់ធនាគារ និងជំរុញឱ្យធនាគារអាចផ្តល់ហិរញ្ញប្បទានបន្ថែមទៅកាន់ SMEs ដែលមានសក្តានុពលកាន់តែច្រើន។ ដោយឡែក ក្រោមគម្រោង ESGS, CGCC នឹងផ្តល់ការធានាលើកម្ចីអាជីវកម្មថ្មីរបស់ធនាគារ ឈីហ្វដែលផ្តល់ដល់ក្រុមហ៊ុន/អាជីវកម្ម រួមទាំងសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) និងក្រុមហ៊ុនធំៗ ជាមួយនឹងវិសាលភាពនៃការធានារហូតដល់ ៩០% នៃប្រាក់ដើម និងលក្ខខណ្ឌធានាអនុគ្រោះនានា។ គម្រោង WGS និង ESGS នឹងចូលរួមចំណែកគាំទ្រធនាគារ ឈីហ្វ ក្នុងការពង្រីកលទ្ធភាពផ្តល់ហិរញ្ញប្បទានសម្រាប់អាជីវកម្មដែលប្រឈមនឹងបញ្ហាកង្វះទ្រព្យធានា ព្រមទាំងរួមចំណែកដល់ការអភិវឌ្ឍវិស័យឯកជន និងភាពធន់នៃសេដ្ឋកិច្ចកម្ពុជា៕

**អំពី CGCC**

CGCC គឺជាសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២០ ក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។ CGCC មានបេសកកម្មចម្បងក្នុងការផ្តល់ការធានាឥណទាន ដើម្បីបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ច។ ផលិតផល និងសេវាកម្មសំខាន់ៗរបស់ CGCC រួមមាន ការធានាលើកម្ចីអាជីវកម្ម ការធានាលើការបោះផ្សាយសញ្ញាបណ្ណ និងការកសាងសមត្ថភាពសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs)។ គិតត្រឹមបំណាច់ខែមេសា ឆ្នាំ២០២៦ CGCC បានផ្តល់ការធានាលើកម្ចីអាជីវកម្មចំនួន ៩.៨០៨ គណនីក្នុងទំហំសរុប ៥៦៧,៦៣ លានដុល្លារអាមេរិក។

**អំពីធនាគារ ឈីហ្វ**

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក គឺជាធនាគារពាណិជ្ជមួយនៅកម្ពុជា ដែលផ្តល់ដំណោះស្រាយហិរញ្ញវត្ថុដែលអាចទុកចិត្តបាន និងមានភាពបត់បែន ដល់បុគ្គល និងអាជីវកម្ម ដោយផ្តោតជាពិសេសលើ SMEs។ ធនាគារ ឈីហ្វ បានទទួលអាជ្ញាបណ្ណប្រតិបត្តិការជាធនាគារឯកទេស នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ហើយបន្ទាប់មកបានទទួលអាជ្ញាបណ្ណធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨។ ធនាគារ ឈីហ្វ ផ្តល់សេវាហិរញ្ញវត្ថុជាច្រើន រួមមាន ប្រាក់បញ្ញើ ឥណទាន សេវាទូទាត់ និងដំណោះស្រាយហិរញ្ញវត្ថុសម្រាប់អាជីវកម្ម ដើម្បីគាំទ្រសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅកម្ពុជា។

គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ ធនាគារ CHIEF BANK បានរាយការណ៍ពីទ្រព្យសកម្មសរុបចំនួន ៤០២ លានដុល្លារអាមេរិក ដែលកើនឡើង ៤៣% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ដោយមានប្រាក់កម្ចី និងបុរេប្រទានសរុប

ចំនួន ២៧៧ លានដុល្លារ និងប្រាក់បញ្ញើអតិថិជនសរុបចំនួន ២៩៥ លានដុល្លារ។ លទ្ធផលទាំងនេះឆ្លុះបញ្ចាំងពីភាពរឹងមាំផ្នែកមូលធន ការគ្រប់គ្រងហានិភ័យប្រកបដោយប្រយ័ត្នប្រយែង និងទំនុកចិត្តជាបន្តរបស់អតិថិជនចំពោះធនាគារ CHIEF BANK។

ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦
**សាជីវកម្មធានាឥណទានកម្ពុជា**